ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

លេខ ១១៩៤ អ.ក.ម.ហ.ល.៧៨

# សេចក្តីណែនាំ
## ស្តីពី
## ការត្រួតពិនិត្យក្នុងអំឡុងពេល និងក្រោយពេល នៃការអនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានដាក់ចេញនូវនីតិវិធីនានា សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះរួមមាននីតិវិធីក្នុងការរៀបចំគម្រោង កិច្ចលទ្ធកម្ម ការគ្រប់គ្រងកិច្ចសន្យា និងការទុកដាក់ឯកសារនានាពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍ទាំងនោះ។

ដើម្បីធានាដល់ការអនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិទាន់ពេលវេលា និងត្រឹមត្រូវទៅតាមនីតិវិធីនិងបទដ្ឋានបច្ចេកទេស ព្រមទាំងធានាដល់ភាពត្រឹមត្រូវនៃការរៀបចំឯកសារគម្រោង អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំអំពីនីតិវិធីនៃការត្រួតពិនិត្យក្នុងអំឡុងពេល និងក្រោយពេលនៃការអនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម ៖

### ១. ការត្រួតពិនិត្យក្នុងអំឡុងពេលអនុវត្តគម្រោង

### ១.១. គោលបំណងនៃការត្រួតពិនិត្យក្នុងអំឡុងពេលអនុវត្តគម្រោង

គោលបំណងនៃការត្រួតពិនិត្យក្នុងអំឡុងពេលអនុវត្តគម្រោង គឺដើម្បី ៖

- ជំរុញឱ្យការអនុវត្តគម្រោងទាន់ពេលវេលា និងត្រឹមត្រូវតាមនីតិវិធី និងបទដ្ឋានបច្ចេកទេស
- កែលម្អឱ្យបានទាន់ពេលវេលាអំពីចំណុចខ្វះខាតដែលកើតមានឡើងក្នុងការអនុវត្តគម្រោង។

### ១.២. នីតិវិធីនៃការត្រួតពិនិត្យក្នុងអំឡុងពេលអនុវត្តគម្រោង

ការត្រួតពិនិត្យក្នុងអំឡុងពេលអនុវត្តគម្រោងមានជំហានដូចខាងក្រោម ៖

**ជំហានទី១ ៖ ការកំណត់តំបន់គោលដៅ និងគម្រោងសម្រាប់ចុះត្រួតពិនិត្យ**

នាយកដ្ឋានមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការ និងការគាំទ្រពីផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិនៃអនុកម្មវិធីទី២ ត្រូវកំណត់តំបន់គោលដៅ និងគម្រោងសម្រាប់ការត្រួតពិនិត្យក្នុងអំឡុងពេលអនុវត្ត។ ក្នុងការកំណត់នេះ ត្រូវផ្តោតទៅលើគម្រោង ឬតំបន់ណាដែលមានការយឺតយ៉ាវ និងឬមានបញ្ហា។

**ជំហានទី២ ៖ ការរៀបចំកម្មវិធីចុះត្រួតពិនិត្យ**

នាយកដ្ឋានមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការ

និងការគាំទ្រពីផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិនៃអនុកម្មវិធីទី២ ត្រូវរៀបចំកម្មវិធី និងសមាសភាពចូលរួមក្នុងការចុះត្រួតពិនិត្យនេះ ហើយដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានពិនិត្យ និងសម្រេច។ បន្ទាប់ពីបានទទួលនូវការឯកភាពពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន កម្មវិធីចុះត្រួតពិនិត្យនេះត្រូវជម្រាបជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

**ជំហានទី៣ ៖ ការចុះត្រួតពិនិត្យផ្ទាល់**

ក្រុមការងារដែលបានកំណត់នៅជំហានទី២ ត្រូវ ៖

- ពិនិត្យទៅលើឯកសារនានា ដើម្បីកំណត់អំពីភាពត្រឹមត្រូវ និងភាពមិនប្រក្រតីនៃឯកសារ (បញ្ជីឯកសារពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍មាននៅក្នុងឧបសម្ព័ន្ធទី១)។ ភាពមិនប្រក្រតីនៃឯកសារ ៖ ការខ្វះឬបាត់ឯកសារ ការក្លែងបន្លំឯកសារ ការចុះកាលបរិច្ឆេទនៃឯកសារ ការខុសគ្នានៃចំនួននិងតម្លៃលទ្ធផលនៃឯកសារនីមួយៗ សញ្ញានានានៃការឃុបឃិតស៊ុមគ្រលំគ្នា។ល។
- ចុះពិនិត្យផ្ទាល់នៅទីតាំងគម្រោង។ ក្នុងការចុះពិនិត្យនេះ ត្រូវ ៖
  - សាកសួរអ្នកទទួលផល អ្នកទទួលរងនូវផលប៉ះពាល់គម្រោង ឬអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យដឹងថា តើកិច្ចដំណើរការនៃការរៀបចំគម្រោង កិច្ចលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា ត្រូវបានអនុវត្តទៅតាមនីតិវិធីត្រឹមត្រូវដែរឬទេ។
  - វាស់វែង និងធ្វើតេស្តសាកល្បងលទ្ធផលគម្រោង ដើម្បីប្រាកដថា ចំនួន និងគុណភាពលទ្ធផលស្របទៅតាមល័ក្ខខ័ណ្ឌកិច្ចសន្យា និងបទដ្ឋានបច្ចេកទេស។
- រៀបចំរបាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការត្រួតពិនិត្យ ដោយលើកឡើងឱ្យបានច្បាស់លាស់នូវចំណុចដែលបានអនុវត្តត្រឹមត្រូវ និងចំណុចដែលអនុវត្តមិនបានត្រឹមត្រូវ ដើម្បីកែលម្អការអនុវត្ត។
- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលនៃការត្រួតពិនិត្យ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលខ្លួនបានចុះត្រួតពិនិត្យដើម្បីរាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យ នៅមុនពេលចាកចេញពីរដ្ឋបាលថ្នាក់ក្រោមជាតិនោះ។ គ្រប់ការចុះត្រួតពិនិត្យទាំងអស់ត្រូវរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលនៃការត្រួតពិនិត្យ។ អ្នកចុះត្រួតពិនិត្យត្រូវភ្ជាប់កំណត់ហេតុនៃកិច្ចប្រជុំនេះ ជាមួយរបាយការណ៍របស់ខ្លួន ដើម្បីជាភស្តុតាង។

**ជំហានទី៤ ៖ ការរៀបចំរបាយការណ៍ពិស្តារស្តីពីលទ្ធផលនៃការត្រួតពិនិត្យ**

នៅពេលត្រឡប់មកដល់ការិយាល័យវិញភ្លាម ក្រុមការងារត្រូវរៀបចំរបាយការណ៍ពិស្តារស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ ហើយដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន តាមរយៈប្រធាននាយកដ្ឋានមានសមត្ថកិច្ច ដើម្បីពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបាននូវការឯកភាពពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន របាយការណ៍នេះត្រូវថតចម្លង និងផ្ញើជូនរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

**ជំហានទី៥ ៖ ការតាមដានការអនុវត្តតាមអនុសាសន៍**

នាយកដ្ឋានមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការនិងការគាំទ្រពីផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិនៃអនុកម្មវិធីទី២ ត្រូវតាមដានទៅលើការអនុវត្តតាមអនុសាសន៍ ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ចាត់វិធានការដោះស្រាយ ឬកែតម្រូវនូវចំណុចខ្វះខាតទៅតាមអនុសាសន៍របស់ក្រុមការងារចុះត្រួតពិនិត្យ។ ក្នុងករណីចាំបាច់ នាយកដ្ឋានមានសមត្ថកិច្ចអាចចាត់

បញ្ជូនមន្ត្រីជំនាញចុះទៅពិនិត្យការអនុវត្តតាមអនុសាសន៍ទាំងនោះ។

ក្រៅពីសកម្មភាពខាងលើនេះ នៅក្នុងការត្រួតពិនិត្យក្នុងអំឡុងពេលអនុវត្តគម្រោង នាយកដ្ឋានមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការ និងការគាំទ្រពីផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិនៃអនុកម្មវិធីទី២ ត្រូវតាមដាន និងជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ៖

- ជ្រើសរើសគម្រោងវិនិយោគប្រចាំឆ្នាំរបស់ខ្លួនឱ្យបានទាន់ពេលវេលា ដោយស្នើសុំឱ្យទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តផ្ញើបញ្ជីគម្រោងវិនិយោគប្រចាំឆ្នាំរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ យ៉ាងយូរត្រឹមដំណាច់ខែធ្នូនៃឆ្នាំនីមួយៗ។ ការជ្រើសរើសគម្រោងវិនិយោគមិនទាន់ពេលវេលា នឹងបណ្តាលឱ្យយឺតយ៉ាវដល់ដំណើរការទាំងមូលនៃការរៀបចំ និងការអនុវត្តគម្រោង។
- សិក្សាគម្រោង អនុវត្តកិច្ចលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យារបស់ខ្លួនឱ្យបានទាន់ពេលវេលា ដោយស្នើសុំឱ្យទីចាត់ការផែនការ និងវិនិយោគរាជធានី ខេត្តផ្ញើបច្ចុប្បន្នភាពអំពីវឌ្ឍនភាពនៃការរៀបចំ និងអនុវត្តគម្រោងប្រចាំខែ និងផ្ញើមកនាយកដ្ឋានមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន។ បន្ទាប់មកនាយកដ្ឋានមានសមត្ថកិច្ច រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការរៀបចំ និងអនុវត្តគម្រោងប្រចាំខែជូនអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន។

## ២. ការត្រួតពិនិត្យក្រោយពេលអនុវត្តគម្រោង

### ២.១. គោលបំណងនៃការត្រួតពិនិត្យក្រោយពេលអនុវត្តគម្រោង

គោលបំណងនៃការត្រួតពិនិត្យក្រោយពេលអនុវត្តគម្រោង គឺដើម្បី ៖

- លើកកម្ពស់នូវភាពត្រឹមត្រូវទៅតាមនីតិវិធី និងបទដ្ឋានបច្ចេកទេសក្នុងការអនុវត្តគម្រោង
- ដោះស្រាយនូវចំណុចខ្វះខាតដែលបានកើតឡើងក្នុងការអនុវត្តគម្រោង
- ជំរុញឱ្យមានការថែទាំលទ្ធផលគម្រោង។

### ២.២. នីតិវិធីនៃការត្រួតពិនិត្យក្រោយពេលអនុវត្តគម្រោង

ការត្រួតពិនិត្យក្រោយពេលអនុវត្តគម្រោងមានជំហានដូចខាងក្រោម ៖

**ជំហានទី១ ៖ ការកំណត់តំបន់គោលដៅ និងគម្រោងសម្រាប់ចុះត្រួតពិនិត្យ**

នាយកដ្ឋានមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការ និងការគាំទ្រពីផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិនៃអនុកម្មវិធីទី២ ត្រូវកំណត់តំបន់គោលដៅ និងគម្រោងសម្រាប់ការត្រួតពិនិត្យក្រោមពេលអនុវត្ត តាមវិធីសាស្ត្រចៃដន្យ និងទៅតាមតំបន់នានា ដូចជាតំបន់ខ្ពង់រាប តំបន់វាលទំនាប និងតំបន់សមុទ្រជាដើម។ គម្រោងដែលត្រូវធ្វើការត្រួតពិនិត្យក្រោយពេលអនុវត្ត គឺជាគម្រោងដែលជាការងារសាងសង់ ឬការផ្តល់សេវាកម្មត្រូវបានអនុវត្តចប់សព្វគ្រប់។

**ជំហានទី២ ៖ ការរៀបចំកម្មវិធីចុះត្រួតពិនិត្យ**

នាយកដ្ឋានមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការ និងការគាំទ្រពីផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិនៃអនុកម្មវិធីទី២ ត្រូវរៀបចំកម្មវិធី និងសមាសភាពចូលរួមក្នុងការចុះត្រួតពិនិត្យនេះ ហើយដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ពិនិត្យ និងសម្រេច។

បន្ទាប់ពីបានទទួលនូវការឯកភាពពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន កម្មវិធីចុះត្រួតពិនិត្យនេះត្រូវជម្រាបជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ។

**ជំហានទី៣ ៖ ការចុះត្រួតពិនិត្យ**

ក្រុមការងារដែលបានកំណត់នៅជំហានទី២ ត្រូវ ៖

- ពិនិត្យទៅលើឯកសារនានា ដើម្បីកំណត់អំពីភាពត្រឹមត្រូវ និងភាពមិនប្រក្រតីនៃឯកសារ (បញ្ជីឯកសារពាក់ព័ន្ធនឹងការអនុវត្តគម្រោងអភិវឌ្ឍន៍មាននៅក្នុងឧបសម្ព័ន្ធទី១)។ ភាពមិនប្រក្រតីនៃឯកសារ ៖ ការខ្វះឬបាត់ឯកសារ ការក្លែងបន្លំឯកសារ ការចុះកាលបរិច្ឆេទនៃឯកសារ ការខុសគ្នានៃចំនួននិងតម្លៃលទ្ធផលនៃឯកសារនីមួយៗ សញ្ញានានានៃការឃុបឃិតស៊ីមគ្រលំគ្នា។ល។
- ចុះពិនិត្យផ្ទាល់នៅទីតាំងគម្រោង។ ក្នុងការចុះពិនិត្យនេះ ត្រូវ ៖
  - សាកសួរអ្នកទទួលផល អ្នកទទួលរងនូវផលប៉ះពាល់គម្រោង ឬអ្នកពាក់ព័ន្ធនានា ដើម្បីឱ្យដឹងថា តើកិច្ចដំណើរការនៃការរៀបចំគម្រោង កិច្ចលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា ត្រូវបានអនុវត្តទៅតាមនីតិវិធីត្រឹមត្រូវដែរឬទេ។
  - វាស់វែង និងធ្វើតេស្តសាកល្បងលទ្ធផលគម្រោង ដើម្បីប្រាកដថា ចំនួន និងគុណភាពលទ្ធផលស្របទៅតាមល័ក្ខខ័ណ្ឌកិច្ចសន្យា និងបទដ្ឋានបច្ចេកទេស។
- រៀបចំរបាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ ដោយលើកឡើងឱ្យបានច្បាស់លាស់នូវចំណុចដែលបានអនុវត្តត្រឹមត្រូវ និងចំណុចដែលអនុវត្តមិនបានត្រឹមត្រូវ ដើម្បីកែលម្អការអនុវត្ត។
- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលនៃការត្រួតពិនិត្យ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលខ្លួនបានចុះត្រួតពិនិត្យដើម្បីរាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យ នៅមុនពេលចាកចេញពីរដ្ឋបាលថ្នាក់ក្រោមជាតិនោះ។ គ្រប់ការចុះត្រួតពិនិត្យទាំងអស់ត្រូវរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលនៃការត្រួតពិនិត្យ។ អ្នកចុះត្រួតពិនិត្យត្រូវភ្ជាប់កំណត់ហេតុនៃកិច្ចប្រជុំនេះ ជាមួយរបាយការណ៍របស់ខ្លួន ដើម្បីជាភស្តុតាង។

**ជំហានទី៤ ៖ ការរៀបចំរបាយការណ៍ពិស្តារស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ**

នៅពេលត្រឡប់មកដល់ការិយាល័យវិញភ្លាម ក្រុមការងារត្រូវរៀបចំរបាយការណ៍ពិស្តារស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ ហើយដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន តាមរយៈប្រធាននាយកដ្ឋានមានសមត្ថកិច្ច ដើម្បីពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបាននូវការឯកភាពពីអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន របាយការណ៍នេះត្រូវថតចម្លង និងផ្ញើជូនរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

**ជំហានទី៥ ៖ ការតាមដានការអនុវត្តតាមអនុសាសន៍**

នាយកដ្ឋានមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ដោយមានកិច្ចសហការនិងការគាំទ្រពីផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិនៃអនុកម្មវិធីទី២ ត្រូវតាមដានទៅលើការអនុវត្តតាមអនុសាសន៍ ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធចាត់វិធានការដោះស្រាយ ឬកែតម្រូវនូវចំណុចខ្វះខាតទៅតាមអនុសាសន៍របស់ក្រុមការងារចុះត្រួតពិនិត្យ។ ក្នុងករណីចាំបាច់ នាយកដ្ឋានមានសមត្ថកិច្ចអាចចាត់បញ្ជូនមន្ត្រីជំនាញចុះទៅពិនិត្យការអនុវត្តតាមអនុសាសន៍ទាំងនោះ។

គ្រប់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ និងក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២នៃផែនការអនុវត្តរយៈពេល៣ឆ្នាំ របស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវអនុវត្តសេចក្ដីណែនាំនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០១២*

**អគ្គនាយក**

**លេខ_ទី**